**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព**

**សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងព្រះរាជពិធីចម្រើនព្រះជន្ម**

**គម្រប់ ៧៩ យាងចូល ៨០ ព្រះវស្សា**

**១៨.០៦.១៩៣៥ - ១៨.០៦.២០១៥**

**សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព**

**សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីសក្ការៈ !**

នៅក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ គម្រប់ **៧៩** យាងចូល **៨០** ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥ នេះ ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូមសម្តែងនូវសេចក្តីសោមនស្សរីករាយ និងអំណរសាទរយ៉ាងក្រៃលែង រួមជាមួយប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសដ៏មហោឡារិកនេះ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាប្រោសព្រះបរមរាជានុញ្ញាតឲ្យទូលបង្គំ ជាកូន ចៅ ចៅទួត ទាំងអស់ សម្តែងនូវការដឹងគុណប្រកបដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលទ្រង់បានបរិច្ចាក ព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ បំពេញនូវព្រះរាជបេសកកម្ម រួមចំណែកយ៉ាងច្រើនលើសលប់ជួយដល់ការងារសង្គមក្នុងផ្នែកមនុស្សធម៌ជួយដល់ប្រជានុរាស្ត្រទីទ័លក្រជួបប្រទះគ្រោះមហន្តរាយផ្សេងៗ ដើម្បីបុព្វហេតុជាតិមាតុភូមិ តាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នាំមកនូវសុខសន្តិភាពពេញលេញ ដើម្បីស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើនសម្បូររុងរឿង។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមសច្ចា និងបូជារស់កម្លាំងកាយចិត្តដង្ហែតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ និងត្រឹមត្រូវរបស់ **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** លុះត្រាអវសាន្តនៃជីវិត។

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh

08 JUN 2015

ក្នុងព្រះរាជពិធីដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក មានព្រះទសបារមីទេវតារក្សាព្រះមហាស្វេតច្ឆត្រទេវតាឆ្នាំថ្មី និងព្រះរាជតេជានុភាព នៃព្រះរាជវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ មហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ សូមព្រះអង្គប្រកបដោយព្រះរាជសុខុមាលភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ដល់កូន ចៅ ចៅទួត របស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាប្រោសទទួលនូវសេចក្តីក្រាបបង្គំទូលថ្វាយប្រកបដោយស្វាមីភក្តិដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**